## ការច្រឡំអង្គច្បាប់ (mistake of law)

គោលការណ៍នេះ មានមូលដ្ឋានមកពីការមិនដឹងច្បាប់ ដែលមិនអាចចាត់ទុកថា ជាការដោះសារ (excuse)[1] ឲ្យរួចផុតពីការទទួលខុសត្រូវទេ។ ការទទួលស្គាល់នូវការមិនដឹងច្បាប់ ជាការដោះសារឲ្យរួចខ្លួន អាចនឹងលើកទឹកចិត្តប្រជាពលរដ្ឋ មិនឲ្យស្វែងយល់ពីច្បាប់ និង ការទទួលខុសត្រូវផ្លូវច្បាប់។

ទោះបីជា ការច្រឡំអង្គច្បាប់ មិនលុបចោលនូវកំហុស (culpability) វាអាចនាំឲ្យរួចផុតពីការទទួលខុសត្រូវ ប្រសិនបើ ការច្រឡំនោះ នាំឲ្យលុបនូវធាតុផ្សំអត្តនោម័តនៃបទល្មើស (*mens rea*)។ ក្នុងករណីនេះ ការច្រឡំនេះ អាចត្រូវបានគេអះអាងថា វាដូចជាការច្រឡំអង្គហេតុ (mistake of fact)។

បញ្ជារបស់មេបញ្ជាការ (ថៅហ្វាយនាយ) (superior order) អាចពាក់ព័ន្ធនឹងការច្រឡំអង្គហេតុ ដោយសារ គេអាចយល់ថា ការបញ្ជានោះ ត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ ទោះបីជាយ៉ាងនេះក្តី មាត្រា៣៣(២)នៃលក្ខន្តិកៈរបស់ICCបានចាត់ថា បទបញ្ជាឲ្យប្រព្រឹត្តបទប្រល័យពូជសាសន៍ (genocide) និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) គឺខុសច្បាប់យ៉ាងក្រឡែត និងមិនត្រូវចាត់ថាជាការដោះសារទេ។

ពាក់ព័ន្ធថាតើការបញ្ជា ឲ្យប្រព្រឹត្តបទឧក្រិដ្ឋកម្មសង្រ្គាម (war crime) ជាការដោះសារ ឬមិន នៅមិនទាន់មានភាពមិនច្បាស់លាស់នៅឡើយ។ ក៏ប៉ុន្តែ ការបញ្ជាឲ្យសម្លាប់ឈ្លើយសឹក (prisoner of war) និង ជនស៊ីវិល (civilian) គឺខុសច្បាប់ ដោយសារ មានបទប្បញ្ញត្តិ ចែងហាមយ៉ាងច្បាស់ លាស់ហើយក្នុងរឿងនេះ។

នៅមានបញ្ហាស្មុគ្រស្មាញ ថាតើបទបញ្ជារបស់មេបញ្ជាការ ពាក់ព័ន្ធ នឹងច្បាប់ ឬអង្គហេតុ។ ក្រមព្រហ្មទណ្ឌរបស់ប្រទេសមួយចំនួន ដាក់លក្ខខណ្ឌថា ដើម្បីលើកការច្រឡំអង្គច្បាប់មក ជាការដោះសារឲ្យរួចពីការទទួលខុសត្រូវ លុះត្រា សកម្មភាពខុសនោះ ត្រូវបានធ្វើឡើង ផ្អែកលើយោបល់ប្រឹក្សាផ្លូវច្បាប់ជាផ្លូវការ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 422-423)។

**ខ្លឹមសារបន្ថែម៖** ឃ្លាចុងក្រោយ បង្ហាញថា ការច្រឡំត្រូវតែមានហេតុផល។ ជាក់ស្តែង បុគ្គលម្នាក់ពឹងផ្អែកលើយោបល់ផ្លូវច្បាប់ជាផ្លូវការរបស់មេធាវី ដែលអះអាងថា ធ្វើទៅមិនខុសទេ អាចនឹងលើកយកការដោះសារច្រឡំអង្គច្បាប់បាន។

---

[1] ignorance of the law is no excuse (*ignorantia legis non excusat)*